ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៥៩ ប្រក.កសក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១២

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រកាសលេខ១២៩ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្តីពី ការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផលផល
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ស្តីពីការរំសាយឡូត៍នេសាទក្នុងខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ និងរៀបចំជាកន្លែងអភិរក្សផលផល
- បានឃើញអនុក្រឹត្យលេខ ៣៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការលុបឡូត៍នេសាទជុំវិញបឹងទន្លេសាបក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំទុកសម្រាប់

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd , Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone (023) 726 128 / 726 129, Fax : (855) 23 - 217 320

ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារនិងជាកន្លែងអភិរក្សជលផល

- បានឃើញប្រកាសលេខ ១២៩ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារដែលអនុញ្ញាតឲ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## **សម្រេច**

**ប្រការ ១.-**

ត្រូវបានកែសម្រួលប្រការ១និងឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ ១២៩ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារ ដែលអនុញ្ញាតឲ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជាមានដូចតទៅ៖

**ប្រការ ១ថ្មី.-**

ប្រកាសនេះមានគោលបំណងកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារសម្រាប់ធ្វើនេសាទក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា។

ប្រភេទឧបករណ៍នេសាទគ្រួសារសម្រាប់ធ្វើនេសាទក្នុងដែននេសាទទឹកសាប ត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធថ្មីនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ៣
-ឯកសារ កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**ច័ន្ទ សារុន**

## ឧបសម្ព័ន្ធទី

ភ្ជាប់ប្រកាសលេខ...៤៥៨/ប្រក.កសក ចុះថ្ងៃទី...២២....ខែ.តុលា...ឆ្នាំ២០១២

ស្តីពី "ការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារដែលអនុញ្ញាតឲ្យធ្វើនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា" សម្រាប់រដូវបិទនេសាទ

| ល.រ | ប្រភេទឧបករណ៍នេសាទ | ចំនួន | ម៉ែត្រ | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | កង្វារកង្កែប ក្តាម | | | |
| ២ | កង្វារត្រីខ្លួញ | | | |
| ៣ | កំព្រួងជញ្ជាត់ (កំព្រួងជងត្រី) | | | |
| ៤ | កន្សុំ | | | |
| ៥ | ចង្រប់ | | | |
| ៦ | ចាន់ | | | |
| ៧ | ច្បូក | | | មិនប្រើកែវឆ្លុះរួមផ្សំ |
| ៨ | ជីត | | | |
| ៩ | ជុច | | | |
| ១០ | ជួអន្ទង់ | | | |
| ១១ | ឈ្នងដៃ (ឈ្នាងជញ្ជាត់) | | | |
| ១២ | ឈ្នងត្រាំ | | | |
| ១៣ | ឈ្នងអូសឬច្រញខ្ចៅឬលៀស | | | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១៤ | ឈ្នងកង | | | |
| ១៥ | ដៃកាប់ | | | |
| ១៦ | ដៃកឡៀត | | | |
| ១៧ | ដៃកចាក់មានងៀង | | | |
| ១៨ | តុម | | | |
| ១៩ | ថ្នង | | | |

| | | | | |
|---|---|---|---|---|
| ២០ | ទ្រូ | | | |
| ២១ | ប្រម | | | |
| ២២ | ម៉ោងគ្រីឆ្លាំង | | | |
| ២៣ | បំពង់ត្រីកញ្ច្រូក | | | |
| ២៤ | ម៉ោង | | | |
| ២៥ថ្មី | មងបណ្តែត | | ប្រវែងមិនលើសពី១០០ម៉ែត្រ | |
| ២៦ថ្មី | មងពាក់ | | ប្រវែងមិនលើសពី១០០ម៉ែត្រ | |
| ២៧ | លោយ | | | |
| ២៨ | លប | | | មិនប្រើរបាំងព្រួលរួមផ្សំលើសពី១០ម៉ែត្រ<br>ឬមិនលើសពី១/៣ នៃទទឹងមុខទឹក |
| ២៩ | លាន់អន្ទង់ | | | |
| ៣០ | សម | | | |
| ៣១ | ស្ន | | | |
| ៣២ | សាង | | | មិនប្រើតែវន្តះរួមផ្សំ |
| ៣៣ | សៃយ៉ឺន | | | មិនប្រើរបាំងព្រួលរួមផ្សំលើសពី១០ម៉ែត្រ<br>ឬមិនលើសពី១/៣ នៃទទឹងមុខទឹក |
| ៣៤ | សៃយ៉ឺនកំពីស | | | |
| ៣៥ | សន្ទូចផ្លែមួយ | | | |
| ៣៦ | សន្ទូចបោះ | | | |
| ៣៧ | សន្ទូចបបក់ | | | |
| ៣៨ | សន្ទូចបង្កៃ | | | |
| ៣៩ | សន្ទូចរនង | | | |
| ៤០ | ស៊ិងត្រីកញ្ចុះ | | | |
| ៤១ | សំណាញ់ | | | |
| ៤២ | ឡើ | | | |

| | | | | |
|---|---|---|---|---|
| ៤៣ | អង្រុត | | | |
| ៤៤ | អញ្ចាង | | | |

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ១០ ឆ្នាំ ២០១២

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ណៅ_ធួក**

**បានឃើញ និងយល់ព្រម**

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ១៧ ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

**ចាន់_សារុន**

**ឧបសម្ព័ន្ធថ្មី**

ភ្ជាប់ប្រកាសលេខ.....៤៥៨......កសក ចុះថ្ងៃទី២២.... ខែ.ធ្នូ...ឆ្នាំ២០១២

**ស្ដីពី " ការកំណត់ប្រភេទឧបករណ៍នេសាទគ្រួសារដែលអនុញ្ញាតឲ្យធ្វើនេសាទក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា" សម្រាប់រដូវបើកនេសាទ**

| ល.រ | ប្រភេទឧបករណ៍នេសាទ | សេចក្ដីផ្សេងៗ |
|---|---|---|
| ១ | កង្វារកង្កែប ក្ដាម | |
| ២ | កង្វារត្រីឆ្លូញផ្លែ | |
| ៣ | កញ្ច្រែងជញ្ជាត់ (កញ្ច្រែងជងត្រី) | |
| ៤ | កន្សៃ | |
| ៥ | ចង្រ្កប់ | |
| ៦ | ចាន់ | |
| ៧ | ចៃវ៉ា | មិនប្រើម៉ាស៊ីនរុញនិងខ្យល់រួមផ្សំ |
| ៨ | ច្បូក | មិនប្រើកែវឆ្លុះរួមផ្សំ |
| ៩ | ជន | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១០ | ជីត | |
| ១១ | ជុច | |
| ១២ | ជូអន្ទង់ | |
| ១៣ | ឈ្នាងដៃ (ឈ្នាងជញ្ជាត់) | |
| ១៤ | ឈ្នាងក្រាំ | |
| ១៥ | ឈ្នាងអូស ឬ រុញខ្មៅ ឬ លៀស | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ១៦ | ឈ្នាងគង | |
| ១៧ | ឈ្នក់ (ឆ្នុក) | មិនប្រើភ្លើងនិងនុយរួមផ្សំ |
| ១៨ | ដៃកាប់ | |
| ១៩ | ដៃកឈ្មៀត | |

| | | |
|---|---|---|
| ២០ | ដែកចាក់មានជៀង | |
| ២១ | គុម | |
| ២២ | ថ្នង | |
| ២៣ | ទ្រូ | |
| ២៤ | នាម | មិនប្រើម៉ាស៊ីនរួមផ្សំ |
| ២៥ | ប្រម | |
| ២៦ | ប៉ោងត្រីផ្លាំង | |
| ២៧ | បំពង់ត្រីកញ្ច្រែក | |
| ២៨ | ប៉ោង | |
| ២៩ | មងបណ្ដោត | |
| ៣០ | មងពាក់ | |
| ៣១ | លាយ | |
| ៣២ | លប | មិនប្រើរបាំងព្រួលលើសពី១/២ នៃទទឹងមុខទឹក |
| ៣៣ | លាន់អន្ទង់ | |
| ៣៤ | សម | |
| ៣៥ | ស្ន | |
| ៣៦ | សាង | មិនប្រើកែវឆ្លុះរួមផ្សំ |
| ៣៧ | សៃយ៉ឺន | មិនប្រើរបាំងព្រួលលើសពី១/២ នៃទទឹងមុខទឹក |
| ៣៨ | សៃយ៉ឺនកំពឹស | |
| ៣៩ | សន្ទូចផ្លែមួយ | |
| ៤០ | សន្ទូចបោះ | |
| ៤១ | សន្ទូចបបក់ | |
| ៤២ | សន្ទូចបង្កៃ | |
| ៤៣ | សន្ទូចរនង | |

| | | |
|---|---|---|
| ៤៤ | ស៊ែងត្រីកញ្ចុះ | |
| ៤៥ | សាប | |
| ៤៦ | សំណាញ់ | |
| ៤៧ | ឡើ | |
| ៤៨ | អង្រុត | |
| ៤៩ | អញ្ចាង | |
| ៥០ | អួនអូសដោយដៃ | ប្រវែងមិនលើសពី១០០ ម៉ែត្រ |

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

ណៅ_ធួក

**បានឃើញ និងយល់ព្រម**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ១១ ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

ចាន់_សារុន